ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

សំណុំរឿងព្រហ្មទណ្ឌលេខ : ២៤១
ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២៣
សាលក្រមព្រហ្មទណ្ឌលេខ : ៥៣៩/៤២ "ជ"
ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០២៣

នាមនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាដំបូងខេត្តព្រះសីហនុ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ ប្រកាសសាលក្រមនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ ដោយមានសមាសភាព ដូចតទៅ:

ចៅក្រមជំនុំជម្រះ

-លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌលេខ: **២៤១ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣** ដែលមាន៖

-ជនជាប់ចោទ ៖

ឈ្មោះ [redacted] **ទឹង** ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ បើកបរ មានទីកន្លែងកំណើត [redacted] ខេត្តកោះកុង មានទីលំនៅបច្ចុប្បន្នមុនពេលឃាត់ខ្លួននៅប៊ុរី BS អូរ៥ ផ្ទះលេខ១៥៨ ក្រុមទី១៧ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] ប៊ុ ។ស់" ម្តាយឈ្មោះ [redacted] គង់ ។ស់" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន" ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៨២ ដ.ប.ឃ.ខ/ឃ/២៣ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣ ។

ជាប់ចោទពីបទ ៖ កាន់កាប់ និងប្រើប្រាសអាវុធខុសច្បាប់ ប្រព្រឹត្តនៅចំណុច ក្រុមទី១៧ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិ ។

-បានឃើញ: ដីកាសន្និដ្ឋានស្តាពរលេខ: ៤៧០ អ.យ.ញ/២៣ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ។

-បានឃើញ: ដីកាដំណោះស្រាយលេខ: ២៣៥ ដ.ស.ស/ឃ/២៣ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ។

-បានឃើញ: ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ ៣០៥៤ តពរ/២៣ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

Scanned with CamScanner

អត្ថហេតុនៃបណ្តឹងចោទប្រកាន់

កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ២៤ និង ០០ នាទីយប់ មានករណីផ្ទុះអាវុធ មួយបានកើតឡើងនៅ ឃុំ BS អូរ៥ ផ្ទះលេខ១៥៨ ក្រុមទី១៧ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ទីង បានយកកាំភ្លើងម៉ាក k59 បាញ់ឡើងលើ ចំនួន ០៣ គ្រាប់ ដើម្បីគម្រាមដល់ភាគីម្ខាងទៀត ខណៈពេលភាគីនោះមានជម្លោះជាមួយថៅកែរបស់ខ្លួន ក្រោយពេលកើតហេតុ សមត្ថកិច្ចនគរបាលក៏បានចុះទៅដល់ទីតាំងកើតហេតុ និងឃាត់ខ្លួនជនជាប់ចោទ ខាងលើ រួមទាំងដកហូតបានវត្ថុតាងមួយចំនួន ដូចមានក្នុងកំណត់ហេតុចាប់យកវត្ថុតាង។

នាពេលសវនាការ

- ជនជាប់ចោទ ឈ្មោះ [redacted] **ទីង** បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនកំពុងអាំងសាច់ហូបនៅផ្ទះរបស់ខ្លួនស្ថិតនៅ ឃុំ BS អូរ៥ ផ្ទះលេខ១៥៨ ក្រុមទី១៧ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ពេលនោះស្រាប់តែមានជនមួយក្រុមបានជិះរថយន្តមកស្រែកឡូឡានៅមុខផ្ទះរបស់ខ្លួន ភ្លាមៗនោះ ខ្លួនបានទូរស័ព្ទរាយការណ៍ទៅសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់លេខ៤ ដើម្បីសូមជួយ អន្តរាគមន៍ដែរ ប៉ុន្តែពុំមានអ្នកទទួលទូរស័ព្ទ ដោយភ័យពេកខ្លួនក៏បានទៅយកកាំភ្លើងដែលលាក់ទុក នៅក្នុងបន្ទប់ដេក យកមកបាញ់ទៅលើចំនួន ០៣ គ្រាប់ ដើម្បីគម្រាមកុំឱ្យក្រុមទាំងនោះបន្តស្រែកឡូឡា តទៅទៀត។ កាំភ្លើងដែលខ្លួនយកមកប្រើប្រាស់នោះជាកាំភ្លើងរបស់ខ្លួន ដែលបានទិញពីជនមិនស្គាល់ ឈ្មោះតម្លៃ ៤៥០ ដុល្លារអាមេរិក ដោយគេបានប្រាប់ខ្លួនថាកាំភ្លើងនោះជាកាំភ្លើងស្របច្បាប់ទើបខ្លួនហ៊ានទិញ។ ក្រោយពេលទិញបានខ្លួនពុំដែលយកដាក់តាមខ្លួនទេ គឺទុកនៅក្នុងបន្ទប់ដេករបស់ខ្លួនរហូត។

-អំណាងចម្លើយសមត្ថកិច្ច ៖ ក្រោយពីទទួលបានពត៌មានពីប្រជាពលរដ្ឋពាក់ព័ន្ធករណីផ្ទុះអាវុធ នៅចំណុចផ្ទះមួយកន្លែងស្ថិតក្នុងឃុំBSអូរ៥ ខ្លួនក៏បានដឹកនាំកម្លាំងសមត្ថកិច្ចចុះទៅទីតាំងកើតហេតុ និង បានឃាត់ខ្លួន ឈ្មោះ [redacted] ទីង ព្រមទាំងដកហូតបានកាំភ្លើងខ្លីម៉ាកK59ចំនួន០១ដើម និងឡតគ្រាប់ កាំភ្លើងចំនួន០២គ្រាប់ ដែលជននេះបានលាក់ទុកក្នុងផ្ទះកើតហេតុនោះផងដែរ ។

-តំណាងអយ្យការបានសន្និដ្ឋានថា៖ តំណាងអយ្យការសូមតម្កល់សេចក្តីចោទប្រកាន់ដូចមាន ក្នុងដីកាសន្និដ្ឋានស្តាពរលេខ: ៨៧០ អ.យ.ញ/២៣ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣ ទាំងមូល។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្លួនបានឆ្លើយសារភាព នៅគ្រប់ដំណាក់កាល ថាពិតជាបានប្រើប្រាស់ និងកាន់កាប់អាវុធដោយខុសច្បាប់ពិតមែន ប៉ុន្តែការ ដែលកូនក្តីខ្លួនហ៊ានទិញ និងទុកអាវុធនៅនឹងផ្ទះរបស់ខ្លួននោះដោយសារតែ កូនក្តីខ្លួនខ្វះការយល់ដឹង យល់ច្រឡំថា អាវុធនោះមានបណ្ណអនុញ្ញាតិហើយគិតថាជាអាវុធស្របច្បាប់ទើបហ៊ានទិញ និងរក្សាទុក បែបនេះ។ សំណូមសូមឱ្យតុលាការសម្រេចបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនផង។

- ជនជាប់ចោទឈ្មោះ [redacted] **ទីង** បាននិយាយសំដីចុងក្រោយនិងសំណូមពរ ៖ សូមឲ្យតុលាការ ជួយបន្ធូរបន្ថយទោសឲ្យខ្លួនផង។

- **ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ**
- **ក្រោយពីបានពិនិត្យកសុតាង និងឯកសារផ្សេងៗក្នុងសំណុំរឿង**
- **ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ**
- **ក្រោយពីបានស្តាប់សំដីចុងក្រោយ និងសំណូមពររបស់ជនជាប់ចោទ**
- **ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

Scanned with CamScanner

សំអាងហេតុ

១-កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ២៤ និង ០០ នាទីយប់ ស្ថិតនៅ ប៊ុរី BS អូរ៥ ផ្ទះលេខ១៥៨ ក្រុមទី១៧ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណី **កាន់កាប់និងប្រើប្រាសអាវុធខុសច្បាប់** មួយបានកើតឡើង ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ ឡាយ ទីង ដោយបានយកកាំភ្លើងម៉ាក k59 បាញ់ឡើងលើ ចំនួន ០៣ គ្រាប់ ដើម្បីគម្រាមដល់ភាគីម្ខាងទៀត ខណៈពេលភាគីនោះមានជម្លោះជាមួយថៅកែរបស់ខ្លួន ក្រោយពេលកើតហេតុ សមត្ថកិច្ចនគរបាលក៏បានចុះទៅដល់ទីតាំងកើតហេតុ និងឃាត់ខ្លួនជនជាប់ចោទ ខាងលើ រួមទាំងដកហូតបានវត្ថុតាងមួយចំនួន រួមមាន៖ អាវុធខ្លីម៉ាកK59 និងបង់មួយ, សំបកកាទូសចំនួន ០២ សំបក, ស្រោមអាវុធចំនួន ០១, គ្រាប់កាំភ្លើងចំនួន ៤ គ្រាប់, បណ្ណសម្គាល់អាវុធខ្លីអង្គភាពកម្លាំងនគរបាលលេខ ខ.អ.ន-៦៧៤០៥ មួយសន្លឹក ។ ក្រោយពីការសាកសួរ សមត្ថកិច្ចក៏បាន បង្កសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តព្រះសីហនុដើម្បីចាត់ការតាមនីតិវិធី។

២-តាមដីកាដំណោះស្រាយលេខ: ២៣៥ ដ.ស.ស/ឃ/២៣ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **ទីង** មកជំនុំជម្រះពីបទ៖ **កាន់កាប់ និងប្រើប្រាសអាវុធខុសច្បាប់** ប្រព្រឹត្តនៅចំណុច ក្រុមទី១៧ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ។

៣-តាមរបាយការណ៍លេខ ៤៧ រ.ប.ក/២៣ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឈ្មោះ [redacted] ទីន ជាចារីប្រព្រឹត្តអំពើ **កាន់កាប់និងប្រើប្រាសអាវុធខុសច្បាប់** ពិតមែន ។

៤-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ទីង បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនពិតជាបានយកកាំភ្លើងបាញ់ទៅលើ ចំនួន ០៣ គ្រាប់ ដើម្បីគម្រាមកុំឱ្យក្រុមម្ខាងទៀតស្រែកឡូឡា នៅខាងមុខផ្ទះរបស់ខ្លួន ពិតមែន ហើយកាំភ្លើងដែលខ្លួនយកមកប្រើប្រាស់នោះជាកាំភ្លើងរបស់ខ្លួន ដែលបានទិញពីជនមិនស្គាល់ ឈ្មោះតម្លៃ ៤៥០ ដុល្លារអាមេរិក ដោយគេបានប្រាប់ខ្លួនថាកាំភ្លើងនោះជាកាំភ្លើងស្របច្បាប់ទើបខ្លួនហ៊ានទិញ។ ក្រោយពេលទិញបានខ្លួនពុំដែលយកដាក់តាមខ្លួនទេ គឺទុកនៅក្នុងបន្ទប់ដេករបស់ខ្លួនរហូត។

៥-ជនជាប់ចោទឈ្មោះ [redacted] ទីង ពិតជាបាន កាន់កាប់ និងប្រើប្រាស់អាវុធ ម៉ាក ម៉ាក k59 ដោយគ្មានការអនុញ្ញាតិ ពិតមែន។

៦-ជនជាប់ចោទឈ្មោះ [redacted] ទីង ជានីតិជន ដែលមានស្មារតី និងសមត្ថភាពយល់ដឹងគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ នូវអំពើដែលខ្លួនបានប្រព្រឹត្ត ។

៧-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ទីង បានធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ដែលអំពើនេះជាអំពើល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ២០ នៃ ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

៨-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: តំណាងអយ្យការសូមតម្កល់សេចក្តីចោទប្រកាន់ដូចមាន ក្នុងដីកាសន្និដ្ឋានស្តាពរលេខ: ៤៧០ អ.យ.ញ/២៣ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣ ទាំងមូល។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ [redacted] **ទឹង** ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ ពីបទ៖ **កាន់កាប់ និងប្រើប្រាសអាវុធខុសច្បាប់** ប្រព្រឹត្តនៅចំណុច ក្រុមទី១៧ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ។

១០-វត្ថុចាប់យករួមមាន៖

-អាវុធខ្លីម៉ាកK59 និងបង់ចំនួនមួយ, សំបកកាំភ្លើងចំនួន ០២ សំបក, ស្រោមអាវុធចំនួន ០១, គ្រាប់កាំភ្លើងចំនួន ៤ គ្រាប់, បណ្ណសម្គាល់អាវុធខ្លីអង្គភាពកម្លាំងនគរបាលលេខ ខ.អ.៩-៦៧៤០៥ មួយសន្លឹក។ វត្ថុចាប់យក់ខាងលើ គឺជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទ ៖ ឈ្មោះ [redacted] **ទឹង** ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ (ដូចមានសាវតារជាតិខាងលើ) ជាក់ពន្ធនាគារកំណត់រយៈពេល **០៦ (ប្រាំមួយ) ខែ** និង ពិន័យជាប្រាក់ចំនួន **៥០០.០០០ (ប្រាំសែន) រៀល** សម្រាប់ដាក់ចូលថវិការដ្ឋ។

ពីបទ ៖ កាន់កាប់ និងប្រើប្រាសអាវុធខុសច្បាប់ ប្រព្រឹត្តនៅចំណុច ក្រុមទី១៧ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ តាមបញ្ញត្តិ មាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ។

២-វត្ថុចាប់យករួមមាន ៖

- អាវុធខ្លីម៉ាកK59 និងបង់ចំនួនមួយ, សំបកកាំភ្លើងចំនួន ០២ សំបក, ស្រោមអាវុធចំនួន ០១, គ្រាប់កាំភ្លើងចំនួន ៤ គ្រាប់, បណ្ណសម្គាល់អាវុធខ្លីអង្គភាពកម្លាំងនគរបាលលេខ ខ.អ.៩-៦៧៤០៥ មួយសន្លឹក ។

ត្រូវរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ទឹង** និងប្រកាសជាសាធារណៈ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជី
ហត្ថលេខា និងត្រា [redacted]

ចៅក្រមជំនុំជម្រះ
ហត្ថលេខា និងត្រា [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃចន្ទ ១១ រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
ខេត្តព្រះសីហនុ, ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣
ក្រឡាបញ្ជី

បានឃើញ
ចៅក្រមជំនុំជម្រះ

[redacted]

[redacted]

Scanned with CamScanner